# MAGNA CHARTA UNIVERSITATUM

## សេចក្ដីផ្ដើម

សាកលវិទ្យាធិការនៃសាកលវិទ្យាល័យនានានៅប្រទេសអឺរ៉ុបដែលបានចុះហត្ថលេខា បានជួបជុំគ្នានៅសាកលវិទ្យាល័យបូឡូញ៉ាដើម្បីប្រារព្ធពិធីគំរប់៩០០ឆ្នាំនៃសាកលវិទ្យាល័យចំណាស់ជាងគេនៅទ្វីបអឺរ៉ុប ដែលបានកើតឡើងតាំងពី៤ឆ្នាំមុនការបំបិទលែងអោយមានជាស្ថាពរនូវព្រំដែនរវាងប្រទេសទាំងឡាយនៃសហគមន៍អឺរ៉ុប ។ ការជួបជុំនេះគឺជាព្រឹត្តិការណ៍ដែលត្រូវបានចារឹកទុកស្ដីអំពីការពង្រឹងនិងរឹតចំណងសហប្រតិបត្តិការទូលាយរវាងប្រជាជាតិអឺរ៉ុបទាំងមូល ហើយសង្ឃឹមថាប្រជាជននិងប្រទេសទាំងអស់អាចយល់ដឹងកាន់តែច្បាស់ថា សាកលវិទ្យាល័យនានានឹងត្រូវបានអំពាវនាវអោយដើរតួនាទីសកម្មនៅក្នុងសហគមអន្តរជាតិដែលប្រកបដោយការប្រែប្រួលឥតឈប់ឈរ ។

## ពិចារណាថា

១. នៅជិតដំណាច់សហស្សវត្សនេះ អនាគតមនុស្សជាតិពឹងផ្អែកជាចំបងលើការអភិវឌ្ឍវប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ហើយចំនុចនេះត្រូវបានបង្កើតឡើងនៅក្នុងមជ្ឈមណ្ឌលវប្បធម៌ ចំណេះដឹង និងការស្រាវជ្រាវនានាដូចដែលតំណាងដោយសាកលវិទ្យាល័យពិតប្រាកដនានា ។

២. ភារកិច្ចរបស់សាកលវិទ្យាល័យទាំងឡាយក្នុងការពង្រីកផ្សាយចំណេះដឹងក្នុងចំណោមមនុស្សជំនាន់ក្រោយបញ្ជាក់ថានៅក្នុងពិភពលោកបច្ចុប្បន្ន សាកលវិទ្យាល័យទាំងនេះត្រូវបំរើសង្គមទាំងមូល ហើយអនាគតនៃវប្បធម៌ សង្គម និងសេដ្ឋកិច្ចរបស់ប្រទេសមួយគឺទាមទារជាពិសេសនូវការវិនិយោគដ៏យកចិត្តទុកដាក់មួយលើការអប់រំបន្ត ។

៣. សាកលវិទ្យាល័យទាំងឡាយត្រូវផ្ដល់អោយមនុស្សជំនាន់ក្រោយនូវការអប់រំ និងការបណ្ដុះបណ្ដាលដែលនឹងអាចបង្រៀនពួកគេ និងអោយពួកគេផ្សព្វផ្សាយបន្តដល់អ្នកផ្សេងទៀត ដើម្បីគោរពភាពចុះសម្រុងគ្នាដ៏ថ្លៃថ្លានៃបរិស្ថានធម្មជាតិ និងជីវិតរបស់ពួកគេ ។

សាកលវិទ្យាធិការនៃសាកលវិទ្យាល័យប្រទេសអឺរ៉ុបដែលបានចុះហត្ថលេខាហើយបានប្រកាសដល់គ្រប់ប្រទេស និងមនសិការៈរបស់ប្រជាជាតិទាំងអស់ពីគោលការណ៍មូលដ្ឋានសំខាន់ៗដែលដាច់ខាតត្រូវគាំទ្រដល់វិជ្ជាជីវៈរបស់សាកលវិទ្យាល័យទាំងនោះ ក្នុងពេលបច្ចុប្បន្ន ក៏ដូចជាគ្រប់ពេលណាៗទាំងអស់ ។

## គោលការណ៍មូលដ្ឋានសំខាន់ៗ

១. សាកលវិទ្យាល័យគឺជាស្ថាប័នស្វ័យភាពមួយនៅក្នុងបេះដូងសង្គម ដែលទទួលបានការរៀបចំខុសៗគ្នាអាស្រ័យទៅតាមភូមិសាស្ត្រ និងកេរ្ដិ៍ដំណែលប្រវត្តិសាស្ត្រ ។ សាកលវិទ្យាល័យផលិត ពិនិត្យ វាយតំលៃ និងបន្តកេរ្ដិ៍វប្បធម៌តាមរយៈការស្រាវជ្រាវ និងបង្រៀន ។

ដើម្បីបំពេញតំរូវការពិភពលោកដែលនៅជុំវិញខ្លួន ការស្រាវជ្រាវនិងការបង្រៀនរបស់សាកលវិទ្យាល័យត្រូវតែឯករាជ្យទាំងផ្នែកចិត្តគំនិត និងសតិបញ្ញា ចេញពីអំណាចនយោបាយទាំងអស់ និងគំនាបសេដ្ឋកិច្ច ។

២. ការបង្រៀន និងការស្រាវជ្រាវនៅតាមសាកលវិទ្យាល័យនានាត្រូវតែមានលក្ខណៈបណ្តុំរីរូម ប្រសិនបើការបង្រៀននោះអាចឆ្លើយតបនឹងបំរែបំរួលតំរូវការ សេចក្តីត្រូវការរបស់សង្គម និងការរីកចំរើននៃចំណេះដឹងវិទ្យាសាស្ត្រ ។

៣. សេរីភាពក្នុងការស្រាវជ្រាវ និងការបណ្តុះបណ្តាលគឺជាគោលការណ៍មូលដ្ឋាននៃការរស់រានរបស់សាកលវិទ្យាល័យ ហើយរដ្ឋាភិបាល និងសាកលវិទ្យាល័យនានាត្រូវធានាចំពោះប្រការសំរាប់តម្រូវការ ដ៏ចាំបាច់នេះ ។

ការច្រានចោលភាពមិនចេះអត់ឱន និងការបើកចំហការប្រាស្រ័យទាក់ទងជានិច្ចកាល សាកលវិទ្យាល័យមួយនឹងក្លាយជាកន្លែងជួបជុំដ៏ប្រសើរសំរាប់គ្រូបង្រៀនទាំងឡាយ ដែលមានសមត្ថ-លទ្ធភាពក្នុងការចែករំលែកចំណេះដឹងដែលខ្លួនមាន ដើម្បីអភិវឌ្ឍសាកលវិទ្យាល័យតាមរយៈការស្រាវជ្រាវ និងនវានុវត្តន៍ ហើយនិស្សិតអាចមានសិទ្ធិទទួល និងស្ម័គ្រចិត្តបង្កើនការយល់ដឹងរបស់គេជាមួយនឹងចំណេះដឹងដែលផ្តល់អោយ ។

៤. សាកលវិទ្យាល័យមួយគឺជាក្រុមប្រឹក្សាភិបាលនៃប្រពៃណីអឺរ៉ុបមនុស្សនិយម ។ ការយកចិត្តទុកដាក់ជាប្រចាំរបស់សាកលវិទ្យាល័យគឺដើម្បីសំរេចចំណេះដឹងជាសកល ហើយដើម្បីបំពេញមុខងាររបស់ខ្លួន សាកលវិទ្យាល័យត្រូវពុះពារតទល់នឹងរបាំងភូមិសាស្ត្រ និងនយោបាយ ហើយនិងត្រូវអះអាងពីតំរូវការជាអាយុជីវិតសំរាប់អោយវប្បធម៌នានាខុសៗគ្នាស្គាល់និងមានអានុភាពរវាងគ្នានឹងគ្នា ។

## មធ្យោបាយ

ដើម្បីសំរេចគោលបំណងទាំងនេះដោយគោរពតាមគោលការណ៍ទាំងឡាយដែលបានចែង គឺទាមទារនូវមធ្យោបាយដែលមានប្រសិទ្ធិភាពនិងសមស្របសំរាប់ស្ថានការណ៍បច្ចុប្បន្ន ។

១. ដើម្បីរក្សាសេរីភាពក្នុងការស្រាវជ្រាវនិងបង្រៀន ឧបករណ៍ដែលសមស្របសំរាប់ទាមទារសេរីភាពទាំងនេះត្រូវតែផ្តល់ដល់គ្រប់សមាជិកនៃសហគមន៍សាកលវិទ្យាល័យ ។

២. ការជ្រើសរើសគ្រូ និងការបង្កើតច្បាប់វិន័យសំរាប់តួនាទីគ្រូបង្រៀន ត្រូវតែឈរលើគោលការណ៍ថា ការស្រាវជ្រាវគឺមិនអាចញែកចេញពីការបង្រៀនបានឡើយ ។

៣. នៅក្នុងអំណោយផលសមស្របសំរាប់កាលៈទេសៈផ្សេងៗ សាកលវិទ្យាល័យនីមួយៗត្រូវធានាអះអាងថា សេរីភាពរបស់និស្សិតត្រូវបានការពារ ហើយនិស្សិតទាំងឡាយរីករាយនឹងលក្ខ័ណ្ឌដែលគេអាចទាមទារចំណេះដឹងវប្បធម៌ និងការបណ្តុះបណ្តាលដែលបំពេញតំរូវការរបស់ពួកគេ ។

៤. សាកលវិទ្យាល័យនានា ជាពិសេសនៅទ្វីបអឺរ៉ុប ត្រូវចាត់ទុកការផ្លាស់ប្តូរពត៌មាននិងឯកសារទៅវិញទៅមក និងការធ្វើគំរោងរួមជាញឹកញាប់សំរាប់ការជំរុញអភិវឌ្ឍន៍ដំណើរការនៃការបង្រៀន ជាប្រការសំខាន់សំរាប់ការបង្កើនចំណេះដឹង ។

ដូច្នេះ ដូចនៅក្នុងឆ្នាំដំបូងបំផុតនានានៃប្រវត្តិសាស្ត្ររបស់គេ ពួកគេធ្វើការជំរុញចលភាពរវាងគ្រូនិងសិស្ស ។ លើសពីនេះ ពួកគេចាត់ទុកគោលនយោបាយទូទៅនៃភាពស្មើគ្នា ឋានៈ ឋានន្តរសក្តិ ការប្រលង (ដោយគ្មានបុរេវិនិច្ឆ័យ

ចំពោះសញ្ញាប័ត្រថ្នាក់ជាតិ)   ហើយនិងរង្វាន់នៃអាហារូបករណ៍ចាំបាច់សំរាប់ការបំពេញបេសកកម្មរបស់ពួកគេនៅក្នុងលក្ខ័ណ្ឌទូទៅនាពេលបច្ចុប្បន្ន។

តាងនាមអោយសាកលវិទ្យាល័យទាំងឡាយ  សាកលវិទ្យាធិការដែលបានចុះហត្ថលេខា  យល់ព្រមធ្វើអ្វីៗទាំងអស់គ្រប់យ៉ាងតាមអំណាចដែលមាន  ដើម្បីជំរុញប្រទេសនីមួយៗ  ក៏ដូចជាអង្គការពហុជាតិនានាដែលពាក់ព័ន្ធ  ក្នុងគោលបំណងកែប្រែ  និងអភិវឌ្ឍគោលនយោបាយរបស់ស្ថាប័នដោយយកចិត្តទុកដាក់ស្របទៅតាមសន្និសញ្ញា Magna Carta ដោយបង្ហាញពីបំណងប្រាថ្នាជាឯកច្ឆន្ទរបស់សាកលវិទ្យាល័យទាំងឡាយដែលត្រូវបានកំណត់និងប្រកាសដោយសេរី។